ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

របាយការណ៍
កិច្ចប្រជុំរួមប្រចាំខែវិច្ឆិកា ឆ្នាំ២០២១
របស់ថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

នៅព្រឹកថ្ងៃចន្ទ ១១រោច ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២១ ចាប់ពីម៉ោង ៩:០០នាទីព្រឹក អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំកិច្ចប្រជុំថ្នាក់ដឹកនាំប្រចាំខែវិច្ឆិកា ឆ្នាំ២០២១ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តមទេសរដ្ឋមន្ត្រី **អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។ កិច្ចប្រជុំនេះមានការចូលរួមពី ឯកឧត្តម លោកជំទាវ លោក អ្នកស្រី និងនាងកញ្ញាជាអនុប្រធាន ទីប្រឹក្សា អគ្គលេខាធិការ នាយកខុទ្ទកាល័យ នាយករងខុទ្ទកាល័យ អគ្គលេខាធិការរង ប្រធាននាយកដ្ឋាន ជំនួយការ ចូលរួមដោយផ្ទាល់នៅសាលប្រជុំ "**ខ**" ដោយឡែកចំពោះ លោក អ្នកស្រី អ្នកនាងកញ្ញា ជាអនុប្រធាននាយកដ្ឋាន ប្រធានការិយាល័យ និងអនុប្រធានការិយាល័យ ចូលរួមតាមបណ្តាញវីដេអូ កម្មវិធី Zoom សរុបចំនួន៣៥នាក់/៣១ គណនី។

គោលបំណងនៃកិច្ចប្រជុំដើម្បី ៖

- ធ្វើបច្ចុប្បន្នភាព សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ និងអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- ត្រួតពិនិត្យ តាមដាន និងវាយតម្លៃពីស្ថានភាពរាលដាល និងការឆ្លើយតបនឹងមេរោគអេដស៍ ។
- ពិនិត្យ វាយតម្លៃពីសមិទ្ធផលដែលសម្រេចបាន និងឧបសគ្គក្នុងការអនុវត្តផែនការសកម្មភាពនិងដាក់ផែនការបន្ត។

ជាកិច្ចចាប់ផ្តើម ឯកឧត្តមទេសរដ្ឋមន្ត្រី និងជាប្រធានអង្គប្រជុំ មានប្រសាសន៍ស្វាគមន៍ ដល់មន្ត្រីរាជការទាំងអស់ដែលបានចូលរួម និងបានដម្រាបជូនពីដំណើរការនៃកិច្ចប្រជុំ តាមរបៀបវារៈដូចខាងក្រោម ៖

១) បទបង្ហាញស្តីពី**គោលដៅ ៩៥-៩៥-៩៥ នៅឆ្នាំ២០២៥** ដោយឯកឧត្តម **ង៉ា ផល** អនុប្រធានទទួលបន្ទុកបច្ចេកទេស។

២) បទបង្ហាញរបាយការណ៍សង្ខេបស្តីពីលទ្ធផលសកម្មភាពការងារប្រចាំខែវិច្ឆិកា និងទិសដៅការងារខែធ្នូ ឆ្នាំ២០២១ ដោយឯកឧត្តម ឈឹម ឃិនដារ៉ែត អគ្គលេខាធិការ។

៣) មតិសំណេះសំណាលរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី។

៤) កិច្ចការផ្សេងៗ។

I- បទបង្ហាញស្តីពីគោលដៅ ៩៥-៩៥-៩៥ នៅឆ្នាំ២០២៥។

ដោយមានការអនុញ្ញាតពី ឯកឧត្តមទេសរដ្ឋមន្ត្រី ឯកឧត្តមវេជ្ជបណ្ឌិត **ង៉ា ផល** អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ទទួលបន្ទុកបច្ចេកទេស បានធ្វើបទបង្ហាញ ៖

- ដើម្បីសម្រេចបានគោលដៅ ៩៥-៩៥-៩៥ នៅឆ្នាំ២០២៥ យើងត្រូវធ្វើឱ្យបានសម្រេចនូវកម្រិតនៃករណីឆ្លងថ្មីធ្លាក់ចុះឱ្យទាបជាង២៥០នាក់ក្នុងមួយឆ្នាំ។
- នៅឆ្នាំ២០២២-២០២៣ យើងនឹងមានធ្វើការវាយតម្លៃទាក់ទងទៅនឹងការធ្វើសមាហរណកម្មក្នុងវិស័យសុខាភិបាល ដើម្បីឱ្យប្រជាពលរដ្ឋទទួលបាននូវសេវាការពារសង្គម។
- មានវិធីសាស្ត្រច្រើនយ៉ាងដើម្បីអនុវត្តជាមួយប្រជាជនគន្លឹះ ដូចជា ចុះជួបដោយផ្ទាល់ តាមប្រព័ន្ធផ្សព្វផ្សាយចុះពេលយប់ (mobile Van) ដើម្បីជម្រុញ:
    - ការធ្វើតេស្តដោយខ្លួនឯង (Selves testing) មានការកើនឡើង។
    - *ផែនការប្រើថ្នាំលេបការពារជំងឺអេដស៍ PrEP* នៅឆ្នាំ២០២៣ ឱ្យបាន១០,០០០ករណី ការចាប់ផ្តើមប្រើនៅឆ្នាំ២០២១នេះ បានត្រឹមតែ១,៦០០ ករណី (គម្រោងមូលនិធិសកល)។
- ការធ្វើតេស្តដើម្បីបញ្ជាក់អំពីការឆ្លងថ្មី ឬករណីចាស់តាមបច្ចេកទិទ្យាទំនើប លទ្ធផលវិជ្ជមានករណីឆ្លងថ្មីមានអត្រា៥% (ភាគច្រើន MSM)។
- ការធ្វើ viral load testing កាន់តែល្អបន្តិចម្តងៗ។
- USAID/PEPFAR បានគាំទ្រនូវគោលនយោបាយរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដែលបានរៀបចំប្រព័ន្ធសុខាភិបាលបានល្អ អាចផ្តល់សេវាដល់ប្រជាពលរដ្ឋដោយសមធម៌ និងមានចីរភាព។
- ត្រូវជំរុញឱ្យប្រជាពលរដ្ឋរងគ្រោះចូលរួមដោយខ្លួនឯង ក្នុងដំណើការដោះស្រាយការរើសអើង អំពើហឹង្សា និងធានាផ្តល់សេវាឱ្យកាន់ តែប្រសើរ។
- ត្រូវជំរុញការចូលរួមឆ្លើយតបនឹងជំងឺអេដស៍នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដោយសមាហរណកម្មជំងឺអេដស៍ទៅក្នុងជំងឺរ៉ាំរ៉ៃ ។
- ជំរុញការគោរពយន្តការសម្របសម្រួលតែមួយ ផែនការយុទ្ធសាស្ត្រតែមួយ ទាំងក្នុងការបង្ការ ការថែទាំ និងការព្យាបាល។
- ចំពោះថ្នាក់ក្រោមជាតិ គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍រាជធានីខេត្ត ត្រូវបញ្ចូលតំណាងអ្នកប្រឈមមុខ និងអ្នកទទួលរងគ្រោះដោយសារជំងឺអេដស៍ មកក្នុងយន្តការដែលមានស្រាប់នៃការឆ្លើយតបអេដស៍។

II- បទបង្ហាញរបាយការណ៍ស្តីពីលទ្ធផលសកម្មភាព ការងាររបស់ថ្នាក់ដឹកនាំ និងអគ្គលេខាធិការដ្ឋាន

ដោយមានការអនុញ្ញាតពី ឯកឧត្តមទេសរដ្ឋមន្ត្រី ឯកឧត្តម **ឈឹម ឃិនជារ៉ែត** អគ្គលេខាធិការ បានធ្វើបទបង្ហាញដោយផ្តោតលើចំណុចសំខាន់ៗស្តីពីលទ្ធផលសកម្មភាពការងារដូចខាងក្រោម ៖

១- សកម្មភាពការងារដែលសម្រេចបាន ៖

- បានទទួលសារលិខិត**សម្តេចតេជោ** សម្រាប់ថ្លែងក្នុងឱកាសប្រារព្ធទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍១ធ្នូ ឆ្នាំ ២០២១។
- បានបញ្ចប់សេចក្តីព្រាងឯកសារប្រព័ន្ធតាមដាន និងត្រួតពិនិត្យអនុវត្ត ស.ជ.ណ២១៣។
- កិច្ចប្រជុំជាមួយអគ្គនាយករដ្ឋបាលហិរញ្ញវត្ថុ រដ្ឋបាលថ្នាក់ក្រោមជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានឯកភាពផ្តល់ថវិកា៨០លានរៀលដល់ រាជធានី ខេត្តនីមួយៗ ដែលបានអនុវត្តគម្រោងទីក្រុងពន្លឿនការឆ្លើយ តបនឹងជំងឺអេដស៍(Fast Track City)។
- បានរៀបចំសេចក្តីព្រាង ដើម្បីបញ្ចូលធាតុចូលក្នុងការពង្រីកការងារទូទាំងប្រទេសឆ្នាំ២០២២។
- បានទំនាក់ទំនងជាមួយទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីរៀបចំអនុក្រឹត្យស្តីពីគោលការណែនាំក្នុងការបង្ការការចម្លងមេរោគអេដស៍ជាសកល។

២- បញ្ហាប្រឈម ៖

- ការអូសបន្លាយនៃការរាតត្បាតមេរោគកូវីដ-១៩ នៅតែបន្តផលប៉ះពាល់ដល់ការធ្វើអន្តរាគមន៍ និងការប្រមូលព័ត៌មាននៃការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍។
- ព័ត៌មានហិរញ្ញប្បទានក្នុងការផ្តល់សាច់ប្រាក់របស់រាជរដ្ឋាភិបាល។

៣- ជំហានសម្រាប់ខែបន្ទាប់ ៖

- បន្តរៀបចំផែនការសកម្មភាពថវិកា និងអនុវត្តសកម្មភាពសម្រាប់ការឆ្លើយតបនឹងមេរោគអេដស៍ ក្រសួងស្ថាប័ន ពិសេស*គម្រោងទីក្រុងពន្លឿនការឆ្លើយតបនឹងជំងឺអេដស៍* (FTC)។
- ការរៀបចំកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី២ រៀបចំសន្និបាតអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ២០-២១ ខែធ្នូ ឆ្នាំ២០២១។
- រៀបចំកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេស។
- រៀបចំវាយតម្លៃរបាយការណ៍ពីសមាជិក និងអង្គការដៃគូរនានា ដើម្បីកំណត់លក្ខណសម្បត្តិនៃការផ្តល់រង្វាន់។
- រៀបចំរបាយការណ៍វឌ្ឍនភាពសមិទ្ធផលឆ្នាំ២០២១ និងត្រៀមបិទបញ្ជី។

III)- **មតិសំណេះសំណាលរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី**

១- ចំពោះអង្គការក្រៅរដ្ឋាភិបាល (NGOs) ឬអង្គការសង្គមស៊ីវិល (CSOs) ដោយសង្កត់ធ្ងន់លើការ***ពង្រឹងប្រព័ន្ធជាតិ*** (strengthening country system) ដើម្បីមកធ្វើការជាមួយគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ រាជធានី/ខេត្ត ក្រុង ស្រុក/ខណ្ឌ និងឃុំ/សង្កាត់។

២- រៀបចំ National data base មួយ ដែលមាន Health & non health information input (ID poor..,) ដែលអនុវត្ត*ការងារជាពហុវិស័យ* ដើម្បីងាយស្រួលក្នុងការតាមដាន និងសម្របសម្រួលការងារអេដស៍។

៣- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានឯកភាពផ្តល់ថវិកា៨០លានរៀល សម្រាប់អនុវត្តគម្រោងទីក្រុងពន្លឿនការឆ្លើយតបនឹងជំងឺអេដស៍ (Fast Track City) នៅរាជធានីភ្នំពេញ ខេត្តសៀមរាប បាតដំបង និងបន្ទាយមានជ័យ ចាប់ពីឆ្នាំ២០២២នេះតទៅ។

៤- ប្រកាសសមាសភាពទីប្រឹក្សាចំនួន៤រូប អគ្គលេខាធិការរងចំនួន៣រូប និងជំនួយការ១រូប។

៥- អ្នកផ្ទុកដែលបានបាត់មុខត្រូវអនុវត្តតាមទិសដៅ២សំខាន់ៗ ទិសដៅទី១) រកឱ្យឃើញអ្នកដែលបាត់មុខទាំងនោះ ឱ្យចូលក្នុងប្រព័ន្ធ ទី២) បង្ការការពារ កុំឱ្យរីករាលដាលនៃជំងឺអេដស៍។

៦- អគ្គលេខាធិការ ត្រូវពិភាក្សាពីផែនការសកម្មភាព ដើម្បីលើកទិសដៅការងារអេដស៍ជាមួយក្រសួងមហាផ្ទៃក្នុងការរៀបចំគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ រាជធានី/ខេត្ត ក្រុង ស្រុក/ខណ្ឌ និងឃុំ/សង្កាត់។

៧- ថ្នាក់ដឹកនាំត្រូវណែនាំដល់ក្រសួង ស្ថាប័ន ឱ្យរៀបចំជារឿងស្តត់ខ្លី។ ស្តីពីMSM អ្នកបាត់មុខ និងទារក ដែលឆ្លងពីមាតា។

៨- សោកស្តាយដែលបានបញ្ចប់តំណែងទីប្រឹក្សា២រូប ដែលអសកម្ម (ពិសេសមិនបានចូលរួមក្នុងកិច្ចប្រជុំប្រចាំខែ) ហើយនឹងមានការផ្លាស់ប្តូរតួនាទីបន្ថែមទៀតនាពេលអនាគត បើសិនជាថ្នាក់ដឹកនាំខ្លះនៅតែអសកម្ម។

៩- អ្នកដែលផ្ទុកមេរោគអេដស៍ បានទទួលអត្តសញ្ញាណប័ណ្ណជនក្រីក្រ តាមការសិក្សាស្រាវជ្រាវបានរកឃើញថា អ្នកផ្ទុកមេរោគអេដស៍ ក្រជាងអ្នកក្រឯទៀត។

១០- យើងនៅបារម្ភពីគោលដៅ៩៥% ទី១ ដោយសារតែក្រុមប្រឈមកើនឡើង ពិសេសបុរសរួមភេទជាមួយបុរស។

១១- ឯកឧត្តមអគ្គលេខាធិការ ត្រូវរាយការណ៍ ពីក្រសួងដែលបានធ្វើរបាយការណ៍ និងបានទទួលថវិកា។

១២- ឯកឧត្តមអគ្គលេខាធិការ ត្រូវរៀបចំលិខិតគោរពជូន **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** ដើម្បីសំណើអញ្ជើញ **ឯកឧត្តម ហោម វណ្ណឌី** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការសម្របសម្រួលជំនួយមូលនិធិសកល (CCC) ជាអ្នកសង្កេតការណ៍ក្នុងកិច្ចប្រជុំពេញអង្គលើកទី២ ដែលនឹងប្រព្រឹត្តទៅនាថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២១។

១៣- ត្រូវពង្រឹងសកម្មភាពលើ MSM ការឆ្លងពីម្តាយទៅទារក ស្វែងរកអ្នកបាត់មុខ និងរៀបចំរចនាសម្ព័ន្ធជាតិ ហៅថា ***ពង្រឹងប្រព័ន្ធជាតិ*** (strengthening country system)។

ជាទីបញ្ចប់ ឯកឧត្តមទេសរដ្ឋមន្ត្រី បានលើកទឹកចិត្ត និងណែនាំឱ្យមន្ត្រីទាំងអស់ បន្តកិច្ចខិតខំប្រឹងប្រែងទាំងអស់គ្នា ដោយយកចិត្តទុកដាក់ក្នុងការងារឱ្យបានកាន់តែប្រសើរឡើង ដោយមានការឯកភាពគ្នាជាធ្លុងមួយ មានសាមគ្គីភាពផ្ទៃក្នុងល្អ។

អង្គប្រជុំបានបញ្ចប់នៅវេលាម៉ោង១១:៣៤នាទី ប្រកបដោយបរិយាកាសរីករាយ និងស្និទ្ធស្នាលក្រៃលែង។

ថ្ងៃពុធ ១២រោច ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២១
អ្នកធ្វើរបាយការណ៍

ស៊ឹម_ចំណាន់

បានឃើញ និងឯកភាព
ទេសរដ្ឋមន្ត្រី ប្រធាន អ.ជ.ប.ជ.អ

អៀង_មូលី